រោងចក្រកាន់តែប្រសើរនៅកម្ពុជា

ព្រឹត្តិបត្រ

លេខ ១១ ខែកញ្ញា ឆ្នាំ២០០៨

# ការឡើងថ្លៃម្ហូបអាហារ ធ្វើអោយកម្មករនិយោជិត និងនិយោជក មានការព្រួយបារម្ភ៖ ការពិនិត្យលើបញ្ហាសង្គមដែលប៉ះពាល់ឧស្សាហកម្មកាត់ដេរ

ការឡើងថ្លៃម្ហូបអាហារនៅជុំវិញពិភពលោក ក្នុងពេលថ្មីៗនេះដោយសារកត្តានានា ដូចជាកំណើនតំរូវការ ការស្តុកទុកជាសកលមានកំរិតទាប និងប្រេងមានតំលៃខ្ពស់ បានបង្កអោយមានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមយ៉ាងធ្ងន់ធ្ងរមកលើសង្គមកម្ពុជា នៅគ្រប់ស្រទាប់វណ្ណៈទាំងអស់។ ប្រទេសកម្ពុជាគឺជាប្រទេសដែលនាំចូលច្រើនជាងនាំចេញ៖ ការឡើងថ្លៃខ្ពស់លើម្ហូបអាហារ និង ប្រេង និងការធ្លាក់តំលៃដុល្លាសហរដ្ឋអាមេរិក បានធ្វើអោយអតិផរណាកើនឡើងដល់ ២៥% នៅក្នុងឆមាសទីមួយ ក្នុងឆ្នាំ ២០០៨ (នេះបើតាមការរាយការណ៍របស់ធនាគារជាតិនៃកម្ពុជា)។ ក្នុងពេលជាមួយគ្នានេះផងដែរ សេដ្ឋកិច្ចក្នុងស្រុកនឹងធ្លាក់ចុះមកត្រឹម ៧,២%។ បញ្ហានេះគឺរឹតតែច្បាស់ថែមទៀតនៅក្នុងឧស្សាហកម្មវាយនភ័ណ្ឌដែលកំណើនការប្រកួតប្រជែង និងការធ្លាក់ចុះសេដ្ឋកិច្ចសហរដ្ឋអាមេរិក មានន័យថាកំណើនការនាំចេញសំលៀកបំពាក់មានល្បឿនយឺត។


ភាគច្រើននៃកម្មករនិយោជិតកាត់ដេរកម្ពុជា ជាស្ត្រីក្មេងៗដែលមកពីតំបន់ជនបទក្រីក្រ

ការកើនឡើងនូវការចំណាយក្នុងជីវភាពរស់នៅ និងការធ្លាក់ចុះនូវតំលៃប្រាក់ឈ្នួលប្រចាំខែ បានបង្កើនភាពងាយរងគ្រោះរបស់គ្រួសារកម្ពុជាអោយទៅជាការភិតភ័យ ជាពិសេសជំងឺ ឬ គ្រោះថ្នាក់។ អវត្តមាននៃសំណាញ់សុវត្ថិភាពសង្គមជាផ្លូវការនៅក្នុងប្រទេសនេះ មានន័យថាគ្រួសារត្រូវតែទទួលយកការភិតភ័យទាំងនេះ ដែលអាចបង្កអោយមានភ័យន្តរាយផ្នែកហិរញ្ញវត្ថុ។ អ្នកដែលងាយរងគ្រោះជាងគេ គឺប្រជាពលរដ្ឋក្រីក្ររស់នៅក្នុងទីក្រុង អ្នកធ្វើចំណាកស្រុកដើម្បីគោលបំណងសេដ្ឋកិច្ចនិងគ្រួសារ កម្មករនិយោជិតដែលមានប្រាក់ឈ្នួលថេរ គ្រួសារជនបទដែលគ្មានដីធ្លី និងក្រីក្រ។ កម្មករនិយោជិតកាត់ដេរកម្ពុជា គឺស្ថិតនៅក្នុងចំណោមអ្នកដែលមានហានិភ័យខ្ពស់ ដោយសារតែពួកគេជាច្រើនគឺជាស្ត្រីក្មេងៗធ្វើចំណាកស្រុកពីតំបន់ជនបទដែលជាអ្នកទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ និងផ្ញើរលុយត្រលប់ទៅផ្ទះវិញហើយជាអ្នកដែលគ្មានបណ្តាញគាំទ្រសង្គមអោយបានគ្រប់គ្រាន់នៅក្នុងបរិស្ថានថ្មីនៅក្នុងទីក្រុងរបស់ពួកគេ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO BFC) បានផ្តួចផ្តើមអោយមានសកម្មភាពចំនួន ២ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ទីមួយ ពិនិត្យលើបទពិសោធន៍ដែលកម្មករនិយោជិតកាត់ដេរមានពាក់ព័ន្ធជាមួយនឹងការផ្លាស់ប្តូរសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ និងទីពីរ បង្កើតអោយមានជាវេទិកាមួយ ដើម្បីពិភាក្សា និងសំរបសំរួលកម្មវិធីនានាដែលផ្តល់ជាការការពារ ឬ ជំនួយទៅអោយកម្មករនិយោជិតកាត់ដេរ។ សកម្មភាពទីមួយត្រូវបានធ្វើឡើងដោយសហការជាមួយនឹងទស្សនាវដ្តីតំលៃនារី និងមានជាការពិភាក្សាក្រុមគោលដៅ ជាមួយនឹងកម្មករនិយោជិតកាត់ដេរ អំពីអារម្មណ៍ និងចំណេះដឹងរបស់ពួកគេ អំពីស្ថានភាពសង្គម និងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ។ នៅក្នុងខែ មេសា និងឧសភា ២០០៨ កម្មករនិយោជិតចំនួន ៧៨ នាក់ បានចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅចំនួន ១៥ ដង។

លទ្ធផលរកឃើញទទួលបានពីការពិភាក្សាក្រុមទាំងនេះ រំលេចនូវអារម្មណ៍អសន្តិសុខ ដែលស្ត្រីមាននៅពេលដែលពួកគេចាកចេញពីស្រុកកំណើត មកធ្វើការនៅក្នុងរោងចក្រ។ ស្ត្រីក្មេងៗភាគច្រើន ដឹងតិចតួចអំពីជីវិតនៅទីក្រុង នៅពេលដែលពួកគេចាកចេញពីភូមិរបស់ពួកគេមក ហើយពួកគេមានមនុស្សតែពីរបីនាក់ប៉ុណ្ណោះ ដែលពួកគេអាចចែករំលែកការព្រួយបារម្ភរបស់ពួកគេជាមួយបាន។ កម្មករនិយោជិតមួយរូបបាននិយាយថា «រស់នៅក្នុងទីក្រុងពិបាកណាស់ នៅពេលដែលគ្មានសាច់ញាតិ ឬ អ្នកជិតខាងដែលយើងអាចចែករំលែកបញ្ហាជាមួយ ហើយយើងត្រូវតែប្រុងប្រយ័ត្នខ្ពស់នៅក្នុងទីក្រុងដ៏សែនគ្រោះថ្នាក់នេះ ជាពិសេសនៅពេលដែលយើងចាកចេញពីរោងចក្រយឺតនៅពេលយប់»។

គ្រោះថ្នាក់ទាំងនេះ ធ្វើអោយស្ត្រីមិនអាចបង្កើតមិត្តភាពថ្មីៗ បង្កើតបណ្តាញគាំទ្រ និងទទួលបានសេវានានាដូចជា សេវាថែទាំសុខភាពជាដើម។ កម្មករនិយោជិតម្នាក់ទៀតបាននិយាយថា «ជីវិតក្នុងទីក្រុង គឺលំបាកណាស់សំរាប់យើង។ យើងមិនដែលដើរចេញទៅខាងក្រៅ ក្រៅតែពីចេញពីផ្ទះជួលទៅរោងចក្រ និងត្រលប់មកផ្ទះវិញតែប៉ុណ្ណោះ»។ ទោះជាយ៉ាងនេះក៏ដោយ ស្ត្រីជាច្រើននាក់នៅតែបន្តធ្វើការងារនៅក្នុងរោងចក្រ ដែលជារឿយៗដោយសារតែពួកគេមានកាតព្វកិច្ចទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ ជាពិសេសដោយសារជារឿយៗ សមាជិកគ្រួសារគឺជាអ្នកផ្តល់លុយជួយពួកគេអោយធ្វើចំណាកស្រុកកាលពីដំបូងឡើយ។

សមត្ថភាពបំពេញកាតព្វកិច្ចនេះ កាន់តែពិបាកទៅៗចំពោះកម្មករនិយោជិតនៅក្នុងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ កម្មករនិយោជិតម្នាក់បាននិយាយថា «ឥឡូវនេះពិបាកសន្សំលុយណាស់ ប៉ុន្តែពួកយើងនៅតែព្យាយាមសន្សំតាមរយៈការកាត់បន្ថយចំណាយរបស់យើង»។ កម្មករនិយោជិតម្នាក់ទៀតបាននិយាយថា «ខ្ញុំខំសន្សំដោយកាត់បន្ថយចំណាយលើការញ៉ាំ ជួនកាលខ្ញុំអត់បាយល្ងាច ហើយខ្ញុំមិនដែលទៅលេងគ្រួសាររបស់ខ្ញុំឡើយ»។ ការឆ្លើយតបបែបនេះ គឺជាការណ៍មួយគួរអោយព្រួយបារម្ភ ដោយសារមូលហេតុចំនួន ២។ ទីមួយ នៅពេលដែលកម្មករនិយោជិតកាត់បន្ថយបរិមាណម្ហូបអាហារដែលពួកគេបរិភោគ ថាមពល និងជីវជាតិរបស់ពួកគេដែលខ្សត់ខ្សោយរួចទៅហើយនោះ

*សូមអានតទៅទំព័រទី ២*

## តួនាទីនាំមុខគេរបស់ឧស្សាហកម្មកាត់ដេរ នៅក្នុងការការពារមាតុភាព

ការការពារមាតុភាព គឺជាកង្វល់ចំបងមួយរបស់អង្គការពលកម្មអន្តរជាតិ (ILO) ចាប់តាំងពីពេលដែលអង្គការនេះ ត្រូវបានបង្កើតឡើង។ ការដាក់អោយប្រើប្រាស់ក្នុងពេលថ្មីៗនេះនូវភាពយន្តឯកសារបែបវិបខាស (webcast) មួយ ស្តីពីការការពារមាតុភាពនៅក្នុងរោងចក្រកាត់ដេរកម្ពុជា ដែលរៀបរាប់ពីគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមទូលំទូលាយដែលព្យាយាមធ្វើអោយស្ត្រីដែលរួមគ្នាបង្កើតកំលាំងពលកម្មចំនួន ៩០% ក្នុងរោងចក្រកាត់ដេរអោយទទួលបានជោគជ័យនៅក្នុងការបញ្ចូលតួនាទីបន្តពូជ និងតួនាទីផលិតភាពរបស់ពួកគេ ដោយគ្មានការរើសអើងយេនឌ័រ។ នៅក្នុងប្រទេសកម្ពុជា ការការពារមាតុភាពពេញលេញ រួមមានការឈប់សំរាកចំនួន ៩០ ថ្ងៃ ដោយទទួលបានប្រាក់ឈ្នួលពាក់កណ្តាល (បូកនឹងប្រាក់រង្វាន់នានា) ការឈប់សំរាកបំបៅដោះកូនដោយមានប្រាក់ឈ្នួល បន្ទប់បំបៅដោះកូន និងទារកដ្ឋាន។ បន្ថែមពីលើនេះ ក្នុងរយៈពេល ២ ខែបន្ទាប់ពីត្រលប់មកពីការឈប់សំរាកលំហែមាតុភាពវិញ កម្មករនិយោជិតអាចតំរូវអោយធ្វើតែការងារស្រាលៗប៉ុណ្ណោះ។


*អ្នកស្រី រស់ គីមស្រៀង ជាកម្មការិនីនៅរោងចក្រ PCCS និងកូនរបស់នាង*

អង្គការពលកម្មអន្តរជាតិទទួលស្គាល់ថា សិទ្ធិរបស់ម្តាយក្នុងការទទួលបាននូវការឈប់សំរាកក្នុងរយៈពេលមួយមុន និងក្រោយការសំរាលកូន គឺមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីការពារសុខភាពម្តាយ និងកូន។ ជាពិសេសនេះពាក់ព័ន្ធជាមួយនឹងអត្រាមរណៈភាពមាតានៅក្នុងប្រទេសកម្ពុជា ដែលជាអត្រាខ្ពស់បំផុតនៅក្នុងតំបន់។ មានស្ត្រីខ្មែរប្រមាណ ២០០០ នាក់ ស្លាប់ជារៀងរាល់ឆ្នាំ ដោយសារមូលហេតុដែលពាក់ព័ន្ធជាមួយនឹងការមានផ្ទៃពោះ និង ការសំរាលកូន។ នៅក្នុងករណីភាគច្រើនការស្លាប់ទាំងនេះគឺអាចបង្ការ

*សូមអានតទៅទំព័រទី ២*

## ផ្នែកខាងក្នុង

បើកវគ្គថ្មីសំរាប់កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលក្នុងឆ្នាំ ២០០៩
សៀវភៅណែនាំច្បាប់ស្តីពីការងារ ត្រូវបានកែសំរួលឡើងវិញ
កញ្ចប់ពិពណ៌ទេសចរណ៍៖ ពិភពនៃកម្មករកម្មការិនីរោងចក្រកាត់ដេរ

# ការឡើងថ្លៃម្ហូបអាហារ ធ្វើអោយកម្មករនិយោជិត និងនិយោជកមានការព្រួយបារម្ភ ៈ...

*តមកពីទំព័រទី ១*



*កម្មករនិយោជិតធ្វើដំណើរទៅធ្វើការនៅរោងចក្រមួយក្បែរទីក្រុងភ្នំពេញ*

នឹងធ្លាក់ចុះ ធ្វើអោយពួកគេកាន់តែឈឺធ្ងន់ជាងមុន និងញឹកញាប់ជាងមុន ពួកគេចាំបាច់ត្រូវចំណាយលុយលើការព្យាបាល និងសុំច្បាប់ឈប់សំរាកឈឺ ធ្វើអោយជីវិតសេដ្ឋកិច្ចកាន់តែធ្លាក់ចុះដុនដាប។ ទីពីរ នៅពេលដែលកម្មករនិយោជិតដែលមានជំងឺ ក្លាយជាកំលាំងពលកម្មដែលមិនសូវមានផលិតភាព វិបត្តិសុខភាពនៅកំរិតតូចៗបែបនេះ មានឥទ្ធិពលលើសេដ្ឋកិច្ចរបស់ប្រទេស ដោយសារផលិតភាពនៅក្នុងវិស័យកាត់ដេរមានការធ្លាក់ចុះ។

នៅពេលដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់ការងារក្នុងរោងចក្រថយចុះជាងមុន ការលើកទឹកចិត្តជាចំបងអោយពួកគេនៅបន្តជីវិតក្នុងរោងចក្រក្នុងទីក្រុង ដោយរស់នៅឆ្ងាយពីគ្រួសារ និងមិត្តភ័ក្រ្តនៅជនបទនឹងថយចុះផងដែរ។ កម្មករនិយោជិតម្នាក់បាននិយាយថា «ខ្ញុំគិតវិលត្រលប់ទៅកាន់គ្រួសាររបស់ខ្ញុំវិញ មិនថាយើងមានអីញ៉ាំឬអត់នោះទេ យ៉ាងហោចណាស់ក៏យើងអាចរស់នៅជាមួយគ្នាបាន។ ខ្ញុំមកទីនេះម្នាក់ឯង ខ្ញុំមានអារម្មណ៍ឯកា ហើយខ្ញុំមិនមានអ្នកដែលខ្ញុំអាចចែករំលែកគំនិតរបស់ខ្ញុំជាមួយបានឡើយ»។

កម្មករនិយោជិតកាត់ដេរភាគច្រើន ចាត់ទុកការងារបច្ចុប្បន្នរបស់ពួកគេជាឱកាសមួយ ដើម្បីមានអនាគតកាន់តែល្អប្រសើរ។ មនុស្សម្នាក់ដែលត្រូវបានសាកសួរ កំពុងសិក្សាគណនេយ្យ ហើយភាគច្រើនបាននិយាយថា ពួកគេចង់បើកអាជីវកម្មតូចមួយនៅក្នុងខេត្តដែលជាស្រុកកំណើតរបស់ពួកគេ។ ដូច្នេះហើយ កំលាំងពលកម្មទាំងនេះមានបំណងប្រាថ្នាធំធេងមួយ ហើយពួកគេចង់ពង្រីកអត្ថប្រយោជន៍ទទួលបានពីការងាររបស់ពួកគេអោយដល់កំរិតអតិបរមា។ ប៉ុន្តែបំណងប្រាថ្នានេះ មិនពាក់ព័ន្ធជាមួយនឹង «ការឡើងឋានៈ» នៅក្នុងឧស្សាហកម្មនេះឡើយ វាផ្តោតលើ «ការចាកចេញ» ពីឧស្សាហកម្មនេះ។

ការព្រួយបារម្ភនេះ បានជំរុញអោយ BFC សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងអ្នកដែលមានតួនាទីនៅក្នុងឧស្សាហកម្មដទៃទៀត ខិតខំរកវិធីបង្កើនការរក្សាចំនួនកម្មករនិយោជិតនៅក្នុងរោងចក្រ។ នាពេលអនាគត BFC នឹងបង្កើនភាពទាក់ទាញរបស់ខ្លួននៅក្នុងផ្នែកនេះ។

ការគូសផែនទីសកម្មភាព ដែលផ្តល់នូវការគាំទ្រ សេវាកម្ម និងការអប់រំទៅអោយកម្មករនិយោជិតកាត់ដេរ បានរំលេចនូវគំរោង និងកម្មវិធីស្រាវជ្រាវជាច្រើនដែលមានគោលបំណងស្វែងយល់អោយបានកាន់តែប្រសើរ និងកែលំអជីវិត និងបង្កើនឱកាសរបស់អ្នកដែលកំពុងធ្វើការនៅក្នុងរោងចក្រកាត់ដេរ។

គំរោងបច្ចុប្បន្នមួយចំនួន រួមមានៈ

- គ្លីនិកសុខភាពផ្លូវភេទ សំរាប់កម្មករនិយោជិតកាត់ដេរដែលអនុវត្តដោយគ្លីនិកចល័តរបស់ឱសថការីគ្មានព្រំដែន (Pharmacies Sans Frontières)
- ជំនាញអប់រំសុខភាព និងបំណិនជីវិតសំរាប់កម្មករនិយោជិតកាត់ដេរ អនុវត្តដោយ CARE និង មូលនិធិកុមាររបស់សហប្រជាជាតិ (UNICEF)
- ការថែទាំផ្ទៃពោះ និងការផ្តល់ថ្នាំជីវជាតិដែកបន្ថែមដល់ស្រ្តីមានផ្ទៃពោះ (CARE និង មន្ទីរសុខាភិបាលក្រុងភ្នំពេញ)
- គ្លីនិកសុខភាពបន្តពូជក្នុងក្រុងភ្នំពេញ អនុវត្តដោយសមាគមសុខភាពបន្តពូជកម្ពុជា (RHAC)
- ការគាំទ្រផ្នែកធនាគារសំរាប់កម្មករនិយោជិតកាត់ដេរផ្តល់ដោយធនាគារភូមិកម្ពុជា (TPC)

រហូតដល់ដំណាច់ឆ្នាំនេះ វាមានគំនិតផ្តួចផ្តើមថ្មីទៀតទាក់ទងនឹងកម្មករនិយោជិតកាត់ដេរ។ គំនិតទាំងនេះមានៈ

- ការផ្ទេរលុយដោយគំរោង Wing សន្សំលុយ និងទូទាត់ប្រាក់ដោយប្រើប្រាស់បច្ចេកវិជ្ជាទូរស័ព្ទដៃចល័ត
- កម្មវិធីសុខភាពបន្តពូជរបស់គំរោង Options ដែលផ្សព្វផ្សាយពីសេវាកម្មផែនការគ្រួសារ និងពត៌មានដល់កម្មករនិយោជិតកាត់ដេរតាមរយៈយុទ្ធនាការផ្សព្វផ្សាយ កម្មវិធីសន្ទនាតាមវិទ្យុ និងធ្វើឱ្យប្រសើរឡើងនូវសេវាកម្មផ្សេងទៀត។
- GRET នឹងចាប់ផ្តើមដំណើរការកម្មវិធីធានារ៉ាប់រងសុខភាពសំរាប់កម្មករនិយោជិតកាត់ដេរ។

| ប្រអប់ពត៌មានៈ ស្ថិតិបច្ចុប្បន្ន ស្តីពីឧស្សាហកម្មកាត់ដេរ | |
|---|---|
| ចំណាយប្រចាំខែលើម្ហូបអាហារ | ២៩ ដុល្លា[១] |
| ចំណាយប្រចាំខែលើការថែទាំសុខភាព | ៦_១១ ដុល្លា[១] |
| ភាគរយនៃកម្មករនិយោជិតដែលរៀបការហើយ | ៤៣%[១] |
| ភាគរយនៃកម្មករនិយោជិតដែលមានកូន | ៣៥%[១] |
| ភាគរយនៃកម្មករនិយោជិតដែលមានគណនីសន្សំ | ០,៥%[២] |
| ភាគរយនៃកម្មករនិយោជិតដែលមានទូរស័ព្ទដៃ | ២៤%[៣] |
| ការធ្លាក់ចុះប្រាក់ឈ្នួលពិតប្រាកដរវាងខែវិច្ឆិកា ២០០៦ និងវិច្ឆិកា ២០០៧ | ៨%[៤] |
| ប្រាក់ឈ្នួលប្រចាំខែគិតជាមធ្យម | ៧២ ដុល្លា[១] |

*សំគាល់ៈ*

*១. GRET ២០០៧ៈ ការស្រាវជ្រាវលើឥរិយាបថសង្គមសេដ្ឋកិច្ច និង សុខភាពក្នុងវិស័យកាត់ដេរ*
*២. TPC ២០០៦ៈ ការស្រាវជ្រាវអំពីគំរោងសន្សំៈ មករា ២០០៦*
*៣. Wing 2006 Project Leather: ការស្រាវជ្រាវបែបគុណវិស័យ*
*៤. CDRI មករា_មិនា ២០០៨ៈ ការពិនិត្យឡើងវិញលើការអភិវឌ្ឍន៍របស់កម្ពុជា ១២ (១)*

គំរោងទាំងនេះមានផលប្រយោជន៍រួមក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខភាព និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចនៃកម្មករកម្មការិនីកាត់ដេរតាមរយៈការផ្តល់សេវាការអប់រំ និងកែលំអសេវាហិរញ្ញវត្ថុ។ ការការពារស្រ្តីពីហានិភ័យសេដ្ឋកិច្ច និងសុខភាពដែលអាចកើតមានឡើងក្នុងតួនាទីជាមាតារបស់ពួកគេ គឺជារឿងដែលគួរឱ្យយកចិត្តទុកដាក់។ បញ្ហានេះ កំពុងតែមានសារៈសំខាន់ ដោយសារតែប្រទេសកម្ពុជា ព្យាយាមសំរេចឱ្យបានគោលដៅកាត់បន្ថយមរណភាពមាតា។

ឥឡូវនេះ ILO BFC កំពុងពិភាក្សាជាមួយនឹង CARE International អំពីការរៀបចំវេទិកាមួយ ជាមួយនឹងដៃគូសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដែលមានកម្មវិធីពាក់ព័ន្ធនឹងឧស្សាហកម្មកាត់ដេរ។ វេទិកាបែបនេះដែលគ្រោងធ្វើក្នុងខែ តុលា ២០០៨ នឹងដើរតួនាទីជាឱកាសភ្ជាប់ទំនាក់ទំនងមួយសំរាប់ការសំរបសំរួលការធ្វើផែនការ ការកសាងសមត្ថភាពគ្នាទៅវិញទៅមក និងជាពិសេសជាវិធីមួយដើម្បីបញ្ចៀសមិនអោយមានការជាន់គំរោងធ្វើការងារខាងបញ្ហាសង្គមសំរាប់ឧស្សាហកម្មកាត់ដេរ។ សង្ឃឹមថាវេទិកាបែបនេះនឹងបង្កើតអោយមានជាការសហការគ្នាធ្វើការងារលើបញ្ហាសង្គមដែលកំពុងមាននាពេលបច្ចុប្បន្នសំរាប់កម្មករនិយោជិតកាត់ដេរកម្ពុជា។

## បើកវគ្គថ្មីសំរាប់កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលក្នុងឆ្នាំ ២០០៩

គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តរជាតិ សហការណ៍ជាមួយ VBNK និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) នឹងចាប់ផ្តើមបើកវគ្គថ្មីសំរាប់កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលក្នុងខែមករា ឆ្នាំ២០០៩។ សិក្ខាសាលាពត៌មានមួយស្តីពីការបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា។ កម្មវិធីបច្ចុប្បន្ន បានលទ្ធផលធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ និងបង្កើនផលិតភាព និងគុណភាពរោងចក្រទាំងឡាយដែលចូលរួមជាមួយ។

កម្មវិធីបណ្តុះបណ្តាលចែកចេញជា ៧ ម៉ូឌុលផ្សេងៗគ្នាដែលត្រូវរៀបចំឡើងនៅក្នុងរយៈពេល ១២ខែ ដោយមាន ២ក្រុមហើយក្រុមនីមួយៗមកពីបណ្តារោងចក្រចំនួន ៧។ ម៉ូឌុលទាំងនេះ រួមមានការកែលំអគុណភាព និងផលិតភាពកម្ពុជាក្នុងបរិបទសកល កិច្ចសហការនៅកន្លែងធ្វើការ សុវត្ថិភាព និងសុខភាពការងារ ការគ្រប់គ្រងធនធានមនុស្ស ល័ក្ខខ័ណ្ឌការងារ និងការកែលំអជាប្រចាំ។ ក្នុងម៉ូឌុលនីមួយៗមានរាប់បញ្ចូលការបង្រៀនដោយអ្នកជំនាញ ទស្សនកិច្ចរោងចក្រ និងគំរោងកែលំអរោងចក្រ។

សំរាប់អ្នកមានចំណាប់អារម្មណ៍ក្នុងកម្មវិធីនេះ សូមអញ្ជើញចូលរួមសិក្ខាសាលាពត៌មាន។ សូមអញ្ជើញចុះឈ្មោះជាមួយកញ្ញា លាង ចន្ធី តាមរយៈអ៊ីម៉េល chanthy@ilo.org ឬទូរស័ព្ទលេខ (៨៥៥_៩២) ៩៧៨ ៥៧៧ ឱ្យបានមុនថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៨។

# តួនាទីនាំមុខគេរបស់ឧស្សាហកម្មកាត់ដេរនៅក្នុងការការពារមាតុភាព

*តមកពីទំព័រទី ១*

បានជាមុន។ នេះមានឥទ្ធិពលធំធេងមកលើចំណូល និង សុខុមាលភាពរបស់គ្រួសារ រួមទាំងលើកម្មករនិយោជិតកាត់ដេរ ដែលជាធម្មតាធ្វើចំណាកស្រុកពីតំបន់ជនបទ ហើយផ្ញើរប្រាក់ឈ្នួលពាក់កណ្តាលរបស់ពួកគេទៅអោយគ្រួសាររបស់ពួកគេនៅផ្ទះវិញ។ ស្រ្តីស្ថិតនៅក្រោមសំពាធ ដើម្បីឧបត្ថម្ភដល់សមាជិកគ្រួសារ ដូច្នេះ ជារឿយៗពួកគេបន្តធ្វើការងារក្នុងរយៈពេលយូរ ពេលមានផ្ទៃពោះ និងឆាប់ចាប់ផ្តើមធ្វើការងារវិញក្រោយពីសំរាលកូន។ ភាពតានតឹងក្នុងកំរិតខ្ពស់ជារឿយៗ ប៉ះពាល់ដល់ខ្លួនប្រាណរបស់ពួកគេ ហើយអាចបង្កើនគ្រោះថ្នាក់ធ្វើអោយមានការពិបាកពេលមានផ្ទៃពោះ។ គ្រោះថ្នាក់បែបនេះ ពិបាកនឹងគ្រប់គ្រងណាស់នៅក្នុងប្រទេសមួយ ដែលជួនកាលសេវាសុខភាពមាតាខ្វះគុណភាព ពិបាកវាយតំលៃ និងកម្មករនិយោជិតភាគច្រើនមិនអាចប្រើប្រាស់បានដោយសារកត្តាសេដ្ឋកិច្ច។

យុទ្ធសាស្រ្តរបស់ក្រសួងសុខាភិបាលកម្ពុជា ២០០៨_២០១៥ បន្តផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើសុខភាពមាតា ដោយកត់សំគាល់ឃើញថាសុខភាពរបស់មាតាមិនទាន់បានរីកចំរើនអោយទាន់ជាមួយនឹងសុខភាពទារកឡើយ ហើយចាំបាច់ត្រូវមានការវិនិយោគអោយច្រើន ប្រសិនបើត្រូវសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់សហប្រជាជាតិ (MDG) ទី ៥ អោយបានមុនឆ្នាំ ២០១៥។

គោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ប្រទេសកម្ពុជា (CMDG) ទី ៥ ដាក់ចេញនូវគោលដៅជាច្រើន ដើម្បីធ្វើអោយកាន់តែប្រសើរនូវសុខភាពមាតាដោយគោលដៅរួម គឺត្រូវកាត់បន្ថយអត្រាមរណភាពមាតាអោយបានពីរភាគបីមុនឆ្នាំ ២០១៥។ ដោយមានប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ ខិតខំសំរេចគោលដៅសុខភាពមាតារបស់ពួកគេ អង្គការពលកម្មអន្តរជាតិក្នុងផ្នែកមួយនៃកម្មវិធីការងារសមរម្យទូលំទូលាយរបស់ខ្លួន បានកំណត់យកចំនុចអាទិភាពចំនួន ៣ ដើម្បីធ្វើអោយកាន់តែប្រសើរនូវសុខភាពមាតា។ ចំនុចទាំងនេះរួមមាន÷ ការបង្កើនការការពារមាតុភាព និង សុខភាពក្នុងកន្លែងធ្វើការ ការអនុវត្តការពង្រីក និងការបង្កើនការការពារសុខភាពសង្គម និងលើកកំពស់អោយមានការងារសមរម្យសំរាប់ភ្នាក់ងារសុខភាព។

នៅកំរិតកន្លែងធ្វើការមានសក្តានុពលធំធេង នៅក្នុងការបង្កើតគោលនយោបាយ ការអប់រំ សេវាកម្ម និង សកម្មភាពជាក់ស្តែង ដើម្បីធ្វើអោយកាន់តែប្រសើរនូវសុខភាពមាតា។ សហជីព និយោជក កម្មករនិយោជិត និងសហគមន៍ អាចរួមគ្នាលើកកំពស់ការយល់ដឹង និងស្វែងរកដំណោះស្រាយចំពោះបញ្ហាសុវត្ថិភាព និងសុខភាពសំខាន់ៗ ដូចជា ការការពារមាតុភាព និងសុខភាពបន្តពូជជាដើម។

ដោយសារតែមូលហេតុនេះហើយ BFC ប្រើប្រាស់កិច្ចសន្ទនា និងភាពជាដៃគូផ្អែកលើកិច្ចសហការនៅកន្លែងធ្វើការនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួនដែលមានគោលបំណងកែលំអល័ក្ខខ័ណ្ឌការងារ និងបង្កើនផលិតភាព។ តាមរយៈការបន្តកិច្ចសន្ទនាបែបនេះ ក្រុមហ៊ុនជាច្រើនកំពុងចាប់ផ្តើមដឹងអំពីតំលៃនៃការការពារមាតុភាព និងការបង្កើនផលិតភាពរបស់សហគ្រាស។

ឥឡូវនេះ ឧស្សាហកម្មកាត់ដេរកំពុងដើរតួនាទីនាំមុខគេ ផ្នែកខាងការការពារមាតុភាព និងអាចជំរុញលើកទឹកចិត្តអោយឧស្សាហកម្មដទៃទៀតអនុវត្តតាមឥរិយាបថ និងវិធីសាស្រ្តស្រដៀងគ្នានេះដោយបង្កើនបទដ្ឋានការងារសំរាប់មនុស្សគ្រប់គ្នា។ ការបង្កើនការយកចិត្តទុកដាក់លើការការពារភាពជាម្តាយ និងមាតុភាព ត្រួសត្រាយផ្លូវអោយមានការងារសមរម្យផង និងមានគ្រួសារល្អនិងតុល្យភាពជីវិតផង។

រោងចក្រភាគច្រើន ដែលត្រូវបានពិនិត្យឃ្លាំមើលដោយ BFC ផ្តល់នូវសមាសធាតុមួយចំនួននៃការការពារមាតុភាព ហើយវីដេអូ (ការផ្សព្វផ្សាយតាមអ៊ីនធឺណិត) របស់ ILO រំលេចនូវសមិទ្ធផលនានា របស់ឧស្សាហកម្មកាត់ដេរនៅក្នុងផ្នែកនេះ។ ចំពោះកម្មករនិយោជិតរោងចក្រ នេះធ្វើអោយមានភាពខុសប្លែកគ្នាយ៉ាងសំខាន់មួយ ចំពោះគុណភាពជីវិតដែលកម្មករនិយោជិត និងគ្រួសាររបស់ពួកគេមាន។ វីដេអូនេះរំលេចនូវភាពចាំបាច់អោយមានការបង្កើនការយកចិត្តទុកដាក់លើការការពារភាពជាម្តាយ និងមាតុភាព និងផ្តល់ពត៌មានស៊ីជំរៅអំពីអត្ថប្រយោជន៍សង្គម ដែលអាចសំរេចទៅបាននៅពេលដែលមាតុភាពត្រូវបានយកចិត្តទុកដាក់ និងត្រូវបានដាក់ជាអាទិភាព។ BFC លើកទឹកចិត្តអោយដៃគូរបស់ខ្លួន ប្រើប្រាស់វីដេអូថ្មីនេះ សំរាប់ការអប់រំ និងការតស៊ូមតិ និងត្រៀមខ្លួនរួចរាល់ដើម្បីពង្រីកការគាំទ្ររបស់ខ្លួននៅក្នុងការយកគោលនយោបាយទាំងនេះមកអនុវត្តជាក់ស្តែង។

សូមប្រើប្រាស់អាស័យដ្ឋានវីដេអូខាងក្រោម ដើម្បីបើកមើលភាពយន្តឯកសារស្តីពីការការពារមាតុភាព។
http://www.ilo.org/global/About_the_ILO/Media_and_public_information/Broadcast_materials/Video_News_Release/lang--en/docName-WCMS_096989/index.htm

# សៀវភៅណែនាំច្បាប់ស្តីពីការងារត្រូវបានកែសំរួលឡើងវិញ

សៀវភៅណែនាំច្បាប់ស្តីពីការងារសំរាប់ឧស្សាហកម្មកាត់ដេរ ដែលត្រូវបានបោះពុម្ពផ្សាយលើកដំបូងក្នុង ឆ្នាំ ២០០៥ ត្រូវបានកែសំរួលឡើងវិញ និង បោះពុម្ពសារជាថ្មី ដើម្បីបញ្ចូលការធ្វើវិសោធនកម្មមាត្រា ១៣៩ និង ១៤៤ របស់ច្បាប់ស្តីពីការងារ និងសេចក្តីជូនដំណឹងលេខ ៧៤៥ ០៦ និង ០៣២ ០៨ ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ សៀវភៅណែនាំនេះ ដែលមានជាភាសាអង់គ្លេស ចិន និងខ្មែរ ផ្តល់ពត៌មានអំពីច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងអនុក្រឹត និងបទបញ្ញានានាដែលពាក់ព័ន្ធរបស់រដ្ឋាភិបាល។ សៀវភៅណែនាំនេះ មានប្រយោជន៍សំរាប់ម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង អ្នកគ្រប់គ្រងធនធានមនុស្ស សហជីព និងតំណាងកម្មករនិយោជិត។ សៀវភៅណែនាំនេះមានតំលៃ ៥ ដុល្លា ហើយអាចស្វែងរកមើលបានតាមវ៉ិបសាយ www.betterfactories.org/ilo.។




---

# កញ្ចប់បណ្តុះបណ្តាលតាមម៉ូឌុលសំរាប់ឧស្សាហកម្មកាត់ដេរកម្ពុជា

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* សហការជាមួយនឹង VBNK ដែលជាដៃគូបណ្តុះបណ្តាលក្នុងស្រុករបស់ខ្លួន បានផលិតនូវកញ្ចប់បណ្តុះបណ្តាល ដែលត្រូវបានរៀបចំឡើងជាពិសេសមួយសំរាប់កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលរបស់ខ្លួន។ កញ្ចប់នេះរួមមាន ស៊ីឌីមួយ ដែលមានគ្រប់ឯកសារបណ្តុះបណ្តាលទាំងអស់ (គំរោងមេរៀន ឯកសារសំរាប់ចែក បទបង្ហាញជា PowerPoint) និងសន្លឹកស្តីពីការអនុវត្តល្អចំនួន ៣៨ សន្លឹក។ មាននៅក្នុងស៊ីឌីនេះផងដែរគឺ សៀវភៅណែនាំសំរាប់អ្នកសំរបសំរួលដែលផ្តល់អោយអ្នកសំរបសំរួល នូវពត៌មានលំអិតអំពីរបៀបរៀបចំ និងអនុវត្តម៉ូឌុលបណ្តុះបណ្តាលនេះ។ សៀវភៅនេះពន្យល់ពីមូលហេតុដែលធ្វើអោយមានកម្មវិធីនេះឡើង ផ្តល់ពត៌មានអំពីរបៀបរៀបចំគណៈកម្មាធិការពិគ្រោះយោបល់នៅកំរិតសហគ្រាស ពន្យល់ពីមាតិការបស់កញ្ចប់នេះ និងផ្តល់អោយអ្នកសំរបសំរួលនូវដំបូន្មានល្អ អំពីរបៀបដឹកនាំវគ្គបណ្តុះបណ្តាលដែលមានការចូលរួម។ សៀវភៅនេះ ក៏ត្រូវបានបោះពុម្ពជា ៣ ភាសាផងដែរ។ គ្រប់ឯកសារទាំងអស់មានជាភាសាខ្មែរ ចិន និងអង់គ្លេស។ សៀវភៅទាំងនេះអាចស្វែងរកបានតាមវ៉ិបសាយ (លើកលែងតែស៊ីឌី) www.betterfactories.org/ilo.។




---

# កញ្ចប់ខិតប័ណ្ណពត៌មានថ្មីស្តីពី*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*

កញ្ចប់ពត៌មានថ្មីៗទាំងនេះ បរិយាយអំពីអ្វីដែល*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*កំពុងធ្វើដើម្បីលើកកំពស់ការងារសមរម្យ នៅក្នុងឧស្សាហកម្មនាំចេញសំលៀកបំពាក់របស់ប្រទេសកម្ពុជា។ កញ្ចប់នេះ រួមមានខិតប័ណ្ណរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដំណើរការពិនិត្យឃ្លាំមើល ការបណ្តុះបណ្តាលតាមម៉ូឌុល និងសន្លឹកពត៌មានអំពីប្រព័ន្ធគ្រប់គ្រងពត៌មាន និង សន្លឹកពត៌មានរបស់*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*ស្តីពី "ជំហានទាំង ១០ សំរាប់កន្លែងធ្វើការដែលកាន់តែមានសុវត្ថិភាព និងសុខភាពល្អ"។

គ្រប់ធនធានខាងលើទាំងអស់នេះ អាចរកបាននៅការិយាល័យ*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ផ្ទះលេខ ៩ ផ្លូវលេខ ៣២២ បឹងកេងកង ១ ចំការមន ក្រុងភ្នំពេញ។







---

# កញ្ចប់ពិព័រណ៌ទេសចរណ៍÷ ពិភពនៃកម្មករនិយោជិតរោងចក្រកាត់ដេរ

កាលពីពេលថ្មីៗនេះ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានផលិតនូវកញ្ចប់ពិព័រណ៍ទេសចរណ៍មួយ ដែលនឹងផ្តល់អោយមនុស្សម្នានូវឱកាសក្រឡេកមើលពិភពរបស់កម្មករនិយោជិតរោងចក្រកម្ពុជា។ កញ្ចប់ពិព័រណ៍នេះ គឺជាកញ្ចប់បែប multimedia ដែលមានគោលបំណងទាក់ទាញការចាប់អារម្មណ៍ចំពោះកម្មវិធី*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* លើកទឹកចិត្តអោយមានការគិតជុំវិញបញ្ហាដែលប៉ះពាល់ដល់កម្មករនិយោជិត និងសំខាន់ជាងគេបង្កើតអោយមាននូវវេទិកាមួយ ដើម្បីអបអរសាទរ និងផ្តល់ការកោតសរសើរចំពោះកម្មករនិយោជិតកាត់ដេររបស់កម្ពុជា។ អ្នកចូលរួមនៅក្នុងពិព័រណ៍នេះ អាចឈានដើរទៅមុខមួយជំហានទៀត កាន់តែទៅជិតកម្មករនិយោជិតកាត់ដេរនៅក្នុងប្រទេសកម្ពុជា តាមរយៈមធ្យោបាយសំលេង និងវីដេអូ ផ្ទាំងរូបភាព រូបថត និងសំលៀកបំពាក់ពិតប្រាកដ ដែលជាជ័យលាភីនៅក្នុងការប្រកួតប្រជែងកម្មវិធី "ខ្ញុំមានតំលៃ" ដាក់តាំងបង្ហាញលើម៉ាឡាកាំង។ កញ្ចប់នេះអាចអោយខ្ចីរហូតដល់រយៈពេល ២ សប្តាហ៍ និងអាចយកទៅប្រើប្រាស់ល្អបំផុត សំរាប់តាំងបង្ហាញនៅទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន ឬ នៅក្នុងព្រឹត្តិការណ៍អ្វីមួយអាចជាការបណ្តុះបណ្តាល ឬ សិក្ខាសាលាដែលប្រធានបទផ្តោតលើផលិតកម្មប្រកបដោយការទទួលខុសត្រូវ។









**ពិពណ៌នេះ រួមមានៈ**

- ពិពណ៌រូបថត "អ្នកដែលនៅពីក្រោយផលិតផល"
- សំលៀកបំពាក់ឆ្នើមចំនួន ៣ ដែលកម្មករនិយោជិតបានរចនាម៉ូដ
- ចំរៀងឆ្នើម ៣ បទជាទំរង់ Mp3 ដែលកម្មករនិយោជិតបាននិពន្ធ និងមានអត្ថបទបោះពុម្ពជាភាសាអង់គ្លេស
- ខ្សែភាពយន្តអំពីការប្រកួតប្រជែង អមជាមួយនឹងបទសំភាសន៍ជាមួយនឹងកម្មករនិយោជិត ម្ចាស់រោងចក្រ និងសមាជិកដទៃទៀតរបស់ឧស្សាហកម្ម
- កូនសៀវភៅពត៌មាន ប័ណ្ណប្រៃសណីយ៍ ផ្ទាំងរូបភាព និងស្លាយបង្ហាញរូបថត អំពីឧស្សាហកម្ម និងល័ក្ខខ័ណ្ឌការងារ

សំរាប់ពត៌មានបន្ថែម សូមទាក់ទង មីនា ម៉ាសកូឡា តាមរយៈអ៊ីមេល maaskola@ilo.org.

# រដ្ឋមន្ត្រីក្រសួងកិច្ចការនារីៈ វិស័យកាត់ដេរនៅតែជារឿងរ៉ាវជោគជ័យ សំរាប់ប្រទេសកម្ពុជា



*លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី*

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី ជឿថា លក្ខខ័ណ្ឌការងាររបស់កម្មករនិយោជិតកាត់ដេរនៅតែបន្តមានការរីកចំរើន ហើយវិស័យកាត់ដេរនៅតែជាវិស័យនាំចេញឈានមុខគេសំរាប់ប្រទេសកម្ពុជា ដោយបង្កើតនូវការងារយ៉ាងច្រើនអនេក សំរាប់យុវជនយុវនារីខ្មែរ បើទោះបីជាមានការព្រួយបារម្ភនៅពេលដែលការដាក់កំហិតរបស់សហរដ្ឋអាមេរិកលើប្រទេសចិន នឹងផុតកំណត់នៅបំណាច់ឆ្នាំនេះក៏ដោយ។

លោកជំទាវរដ្ឋមន្ត្រី បានមានប្រសាសន៍ថា ការទិញប្រកបដោយគុណធម៌កាន់តែមានសារៈសំខាន់ខ្លាំងឡើងៗ មានន័យថា អ្នកបញ្ជាទិញអន្តរជាតិចង់រកប្រភពផលិតផលសំលៀកបំពាក់របស់ពួកគេពីប្រទេសដែលគោរពបទដ្ឋានការងារអន្តរជាតិ និងសិទ្ធិរបស់កម្មករនិយោជិតរបស់ខ្លួន។ លោកជំទាវបានបន្តទៀតថា ប្រទេសកម្ពុជា បាននិងកំពុងធ្វើការងារយ៉ាងជិតស្និទជាមួយនឹងអង្គការពលកម្មអន្តរជាតិ (ILO) និងទីភ្នាក់ងារដទៃទៀត ដើម្បីធានាថាការពិនិត្យឃ្លាំមើលរោងចក្រកាត់ដេរ និងលក្ខខ័ណ្ឌការងារនឹងបន្តមានទៅមុខទៀត ហើយការពិនិត្យឃ្លាំមើលនេះផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រផ្សព្វផ្សាយសំរាប់វិស័យកាត់ដេរ។

លោកជំទាវរដ្ឋមន្ត្រី បានមានប្រសាសន៍ថា «ឧស្សាហកម្មនេះ គឺជាជោគជ័យដ៏ធំមួយតាំងពីដើមមក ប៉ុន្តែយើងដឹងថា មានប្រទេសផ្សេងទៀតដែលចង់បានជោគជ័យបែបនេះផងដែរ»។

ការសិក្សាមួយរបស់ធនាគារពិភពលោកឆ្នាំ ២០០៥ ក៏ផ្តល់នូវពិន្ទុយ៉ាងខ្ពស់ដល់បរិយាកាស «គ្មានការកេងប្រវ័ញ្ចកម្មករនិយោជិត» របស់ឧស្សាហកម្មកាត់ដេរកម្ពុជា។ លក្ខខ័ណ្ឌការងារនៅក្នុងឧស្សាហកម្មដែលមានមូលដ្ឋានក្នុងក្រុងភ្នំពេញ មានលំដាប់ថ្នាក់ខ្ពស់ជាងប្រទេសដទៃទៀតនៅអាស៊ី ដែលមានឧស្សាហកម្មស្រដៀងគ្នានេះ ដូចជា បង់ក្លាដេស ថៃ វៀតណាម និងចិន។

ការអនុវត្តន៍ការងារល្អ បានផ្តល់អោយប្រទេសកម្ពុជានូវឧត្តមភាពប្រកួតប្រជែង និងដាក់ឧស្សាហកម្មនេះ អោយនៅស្ថិតក្នុងមុខតំណែងមួយដែលអាចទាក់ទាញអ្នកវិនិយោគទុនដែលមានការទទួលខុសត្រូវផ្នែកសង្គម។

រហូតមកដល់ខែ មេសា ឆ្នាំ ២០០៨ នេះ មានរោងចក្រកាត់ដេរជាង ៣០០ ដែលមានដំណើរការនៅក្នុងប្រទេសកម្ពុជា ហើយឧស្សាហកម្មនេះ បានផ្តល់ការងារអោយកម្មករនិយោជិតចំនួន ៣៥៤៥៧០ នាក់ នេះបើតាមស្ថិតិរបស់ក្រសួងពាណិជ្ជកម្ម។ បើទោះបីជាការអប់រំរបស់ពួកគេនៅមានកំរិតក៏ដោយក៏ស្ត្រីខ្មែរក្មេងៗ ដែលមកពីខេត្តអាចរកការងារធ្វើតាមរោងចក្របានយ៉ាងងាយ ហើយអាចរកចំណូល ដើម្បីឧបត្ថម្ភជីវភាពគ្រួសាររបស់ពួកគេ។ កម្មករនិយោជិតរោងចក្រជាង ៩០% គឺជាស្ត្រី៖ នេះគឺជាការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងសេដ្ឋកិច្ច និង សង្គមកម្ពុជាទាំងមូល នៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។ និន្នាការនេះងាកចេញពីតួនាទីជាប្រពៃណីរបស់ស្ត្រីខ្មែរដែលជាធម្មតានៅតែផ្ទះ ធ្វើការងារផ្ទះ ហើយត្រូវបានហាមឃាត់មិនអោយធ្វើការងារឆ្ងាយពីផ្ទះ។

ក្រៅពីអ្នកដែលកំពុងធ្វើការងារនៅតាមរោងចក្រ ស្ត្រីខ្មែរភាគច្រើននៅតែធ្វើការងារក្នុងមុខរបរគ្រួសារ ឬ ក្នុងការងារគ្រួសារ ដោយមិនទទួលបានកំរៃ។ រដ្ឋមន្ត្រីក្រសួងកិច្ចការនារីលោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី គូសបញ្ជាក់អំពីភាពចាំបាច់ ដើម្បីផ្តល់ការបណ្តុះបណ្តាលជំនាញទៅអោយស្ត្រីទាំងនេះ សំដៅបង្កើនឱកាសអោយពួកគេទទួលបានការងារកាន់តែល្អប្រសើរជាងមុន។

លោកជំទាវ រដ្ឋមន្ត្រី មានប្រសាសន៍ថា ដោយមើលឃើញពីការរួមចំណែកយ៉ាងសំខាន់របស់ស្ត្រីនៅក្នុងសេដ្ឋកិច្ចជាតិ ក្រសួងកិច្ចការនារីបានផ្តួចផ្តើមអោយមានកម្មវិធីជាច្រើនដែលមានគោលបំណងផ្តល់ការគាំទ្រ និងការពារសិទ្ធិរបស់ស្ត្រី សហការជាមួយនឹងក្រសួងដែលពាក់ព័ន្ធសំខាន់ៗ ដើម្បីលើកកំពស់អោយមានកម្មវិធីបណ្តាញសុវត្ថិភាពសង្គម (ដូចជា នៅក្នុងទីផ្សារក្រៅប្រព័ន្ធ និងសំរាប់អ្នកដែលប្រកបរបរដោយខ្លួនឯង) និងតស៊ូមតិអោយមានសមភាពក្នុងការងារ ដែលសុទ្ធតែជាការរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច នឹងសង្គមជារួម។ ក្រសួងបានចូលរួមនៅក្នុងយុទ្ធនាការលើកកំពស់តំលៃរបស់ស្ត្រី តាមរយៈការប្រកួតប្រជែងនិពន្ធបទចំរៀង និងរចនាម៉ូតសំលៀកបំពាក់ដែលរៀបចំឡើងដោយ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) និងដៃគូរបស់គំរោងនេះ។ ការប្រកួតប្រជែងនេះ មានគោលបំណងបង្ហាញអំពីការចូលរួមចំណែកយ៉ាងសំខាន់របស់កម្មករនិយោជិតកាត់ដេរចំពោះប្រទេសកម្ពុជា និងផ្តល់អោយកម្មករនិយោជិត នូវឱកាសដឹងពីសមត្ថភាពច្នៃប្រឌិត និងទេពកោសល្យរបស់ពួកគេ។

## សំរង់ពត៌មាន

**«ការពិនិត្យឃ្លាំមើលការងារនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជាៈ មេរៀនសំរាប់អាហ្វ្រិក»** – ពិភពសំលៀកបំពាក់ – ៨ កក្កដា ២០០៨

អត្ថបទនេះ រៀបរាប់ពីជោគជ័យរបស់វិស័យកាត់ដេររបស់ប្រទេសកម្ពុជា ចាប់តាំងពីពេលបញ្ចប់កិច្ចព្រមព្រៀងពហុសសៃអំបោះ (MFA) ដែលជាកិច្ចព្រមព្រៀងធ្វើនិយ័តកម្មការនាំចេញសំលៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបក្នុងរយៈពេល ៣០ ឆ្នាំចុងក្រោយនេះ។ អត្ថបទនេះ លើកឡើងជាពិសេសអំពីការពិនិត្យឃ្លាំមើលការងារនៅក្នុងប្រទេសកម្ពុជា និងអំពីរបៀបដែលការពិនិត្យឃ្លាំមើលនេះបានជួយដោះស្រាយបញ្ហាប្រឈមនានា ដែលប៉ះពាល់ដល់កម្មករនិយោជិត ដោយផ្តោតជាសំខាន់លើភាពចាំបាច់យ៉ាងខ្លាំង អោយមានកម្មវិធីពិនិត្យឃ្លាំមើលការងារឯករាជ្យមួយ ដូចជា គំរោងពិនិត្យឃ្លាំមើលសាកល្បងរបស់អង្គការពលកម្មអន្តរជាតិជាដើម ដែលគំរោងបែបនេះ បានបង្កើតនូវមេរៀនដ៏មានសារៈសំខាន់សំរាប់បណ្តាប្រទេសផ្សេងទៀត ជាពិសេស ប្រទេសនៅអាហ្វ្រិក។
http://www.fibre2fashion.com/industry-article/13/1225/labor-monitoring-in-cambodias-garment-industry-lessons-for-africa1.asp

**«ប្រទេសកម្ពុជា ត្រៀមខ្លួនរួចជាស្រេចសំរាប់ការប្រកួតប្រជែងផ្នែកពាណិជ្ជកម្មក្នុងទីផ្សារពិភពលោក»** – វិទ្យុអាស៊ីសេរី ១៤ សីហា ២០០៨ មានតែជាភាសាខ្មែរ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម ចម ប្រសិទ្ធ និយាយអំពីបញ្ហាការអនុវត្តន៍ច្បាប់ស្តីពីការងារនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជាថា ជាឧត្តមភាពប្រកួតប្រជែងដ៏រឹងមាំមួយសំរាប់ប្រទេសនេះ លើបណ្តាប្រទេសដទៃទៀត ហើយក្នុងពេលជាមួយគ្នា ឯកឧត្តមក៏បានលើកឡើងអំពីបញ្ហានានាដែលប្រទេសកម្ពុជាជួបប្រទះពាក់ព័ន្ធជាមួយនឹងការបញ្ចប់ការដាក់កំហិតរបស់សហរដ្ឋអាមេរិកលើផលិតផលរបស់ប្រទេសចិននៅបំណាច់ឆ្នាំនេះ»
http://www.rfa.org/khmer/indepth/Cam-ready-2compete-in-world-trade-market-08142008001317.html

**«*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*»** – វិទ្យុហូល្លង់ – ៣១ សីហា ២០០៨

នៅក្នុងកម្មវិធីនេះ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ត្រូវបានពិពណ៌នាថា ជាគំរោងដែលមានតែមួយគត់ដែលធ្វើការងារដើម្បីកែលំអលក្ខខ័ណ្ឌការងារនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា។ កម្មវិធីនេះ ពិនិត្យឡើងវិញលើប្រវត្តិនៃឧស្សាហកម្មរបស់ប្រទេសនេះ និងសាវតារបស់ការពិនិត្យឃ្លាំមើលការងាររបស់*រោងចក្រកាន់តែប្រសើរ* ដោយបានកត់សំគាល់នូវការរីកចំរើនសំរាប់កម្មករនិយោជិត និង និយោជកដែលកើតឡើងដោយសារតែគំរោងនេះ។
http://www.radionetherlands.nl/thestatewerein/otherstates/tswi-080829-cambodia-labour

# *រោងចក្រកាន់តែប្រសើរ*

## ធ្វើការងារជាមួយនឹងសហជីពលើបញ្ហាថ្មីៗ



*កិច្ចប្រជុំសហជីពដែលប្រព្រឹត្តទៅនៅរោងចក្រកាន់តែប្រសើរកាលពីថ្ងៃទី ៩_កញ្ញា_២០០៨*

នៅក្នុងឆមាសទី ១ ក្នុងឆ្នាំ ២០០៨ នេះ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) នៃអង្គការពលកម្មអន្តរជាតិ បានបង្កើននូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការធ្វើការងារជាមួយនឹងសហជីព សំដៅស្វែងយល់អោយកាន់តែប្រសើរអំពីទស្សនៈវិស័យរបស់សហជីព ទាក់ទងនឹងបញ្ហាការងារ និងបញ្ហាជីវិតបំពេញការងារនៅក្នុងឧស្សាហកម្មកាត់ដេរ។

ជាធម្មតា BFC ធ្វើការងារជាមួយនឹងតំណាងសហជីពមូលដ្ឋាននៅកំរិតរោងចក្រដោយសំភាសន៍ជាមួយពួកគេអំពីលក្ខខ័ណ្ឌការងារក្នុងកំឡុងពេលចុះត្រួតពិនិត្យឃ្លាំមើលលក្ខខ័ណ្ឌការងារនៅក្នុងគ្រប់រោងចក្រកាត់ដេរទាំងអស់ដែលផលិតសំរាប់នាំចេញ។ ការសំភាសន៍បែបនេះ ផ្តល់នូវលំហូរពត៌មានជាក់ស្តែងមួយអំពីលក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រ។ ប៉ុន្តែ វាមិនបានឆ្លុះបញ្ចាំងពីទស្សនៈវិស័យរបស់សហជីព ចេញពីការយល់ឃើញរបស់សហព័ន្ធសហជីពឡើយ។

ចាប់ពីខែ ឧសភា ដល់ មិថុនា ២០០៨ BFC បានរៀបចំអោយមានជាសកម្មភាពចំនួន ២ ដើម្បីស្វែងយល់អោយកាន់តែប្រសើរអំពីកង្វល់របស់សហជីពមូលដ្ឋាន និងសហព័ន្ធសហជីព និងអំពីយុទ្ធសាស្ត្រដែលពួកគេប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាជុំវិញលក្ខខ័ណ្ឌការងារ ធ្វើការចចារ និងសហការគ្នាជាមួយនឹងសហជីពច្រើនផ្សេងទៀតនៅក្នុងសហគ្រាសតែមួយ។

សកម្មភាពទី ១ ដែលធ្វើឡើងនៅថ្ងៃអាទិត្យ ២ ជាប់គ្នា មានការពិភាក្សាជាក្រុម ដែលសំរបសំរួលដោយមន្ត្រីពិនិត្យឃ្លាំមើលលក្ខខ័ណ្ឌការងាររបស់ BFC។ នៅក្នុងការពិភាក្សានេះ បញ្ហាមួយចំនួនដូចខាងក្រោម ត្រូវបានលើកឡើង៖

- តំរូវការអោយមានការយល់ដឹងកាន់តែប្រសើរអំពីការចចារជារួមនៅកំរិតសហជីពមូលដ្ឋាន
- តំរូវការអោយមានភាពល្អប្រសើរជាងមុនក្នុងការជួបជាមួយនឹងអ្នកគ្រប់គ្រងជាន់ខ្ពស់ ដើម្បីពិភាក្សាប្រកបដោយការស្ថាបនា
- ការយល់ឃើញថា ការសហការគ្នាធ្វើការងារជាសហជីពតែមួយ គឺអាចធ្វើទៅបាននៅក្នុងរោងចក្រដោយមិនគិតអំពីកត្តានយោបាយនៅថ្នាក់លើ
- កង្វល់អំពីថាតើកំណើនអត្រាអតិផរណា នឹងមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះមកលើសុខភាព និងជីវភាពរបស់កម្មករនិយោជិត

ជាទូទៅ គ្រប់គ្នាគិតថា ការនាំសមាជិករបស់សហជីពមូលដ្ឋាន មកពីសហជីព និងសហគ្រាសផ្សេងៗគ្នា អោយមកចែករំលែកបទពិសោធន៍របស់ពួកគេ គឺផ្តល់នូវអត្ថប្រយោជន៍យ៉ាងធំធេង។ សមាជិករបស់សហជីពបានលើកឡើងថា ពួកគេមិនដែលធ្លាប់ទទួលបានឱកាសបែបនេះឡើយកន្លងមក ហើយគិតថា ពួកគេទើបតែចេញពីកិច្ចប្រជុំដែលមានលក្ខណៈសំបូរបែប។

សកម្មភាពទី ២ គឺកិច្ចប្រជុំជាមួយនឹងសហពន្ធ័សហជីព ដែលសំរបសំរួលដោយគំរោងអប់រំកម្មករ និយោជិតរបស់អង្គការពលកម្មអន្តរជាតិ នៅក្នុងខែមិថុនា ដែលធ្វើការពិភាក្សាអំពីបញ្ហាបន្ថែម។ ជាពិសេស BFC ចង់ដឹងអំពីរបៀបដែលគំរោងនេះអាចផ្តល់សេវាកាន់តែប្រសើរទៅអោយសហជីព ដើម្បីដោះស្រាយបញ្ហាដែលជាកង្វល់របស់ពួកគេ ដើម្បីអោយឧស្សាហកម្មទាំងមូលអាចបន្តរីកចំរើនទៅមុខទៀត។ បញ្ហា ដែលបានលើកមកពិភាក្សា រួមមានការបង្កើនផលិតភាព បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ និងការប្រាស្រ័យទាក់ទងកាន់តែប្រសើររវាងសហជីពជាមួយនឹង BFC។

កិច្ចប្រជុំនេះ ក៏បានដើរតួជាវេទិកាមួយ ដើម្បីផ្តល់ពត៌មានដល់សហព័ន្ធសហជីពអំពីដំណើរការបន្តរបស់ BFC និងដើម្បីវាយតំលៃមើលថាតើសហជីពគិតថា កម្មវិធីនេះ បន្តមានតំលៃចំពោះសហជីពនៅក្នុងប្រទេសកម្ពុជាដែរឬទេ។ សហជីពដែលមានវត្តមាន បានប្រកាសថា BFC នៅតែបន្តជាផ្នែកមួយយ៉ាងសំខាន់របស់ឧស្សាហកម្ម។ ពួកគេចង់អោយគំរោងនេះបន្តដំណើរការទៀត និងពង្រីកបន្ថែមកិច្ចខិតខំប្រឹងប្រែងចែករំលែកពត៌មាន និងបណ្តុះបណ្តាលរបស់ខ្លួនទៀត ដើម្បីអោយសមាជិកសហជីពកាន់តែច្រើននាក់អាចចូលរួមបាន។

BFC ចង់អោយកិច្ចប្រជុំប្រភេទនេះមានជាបន្តទៀត និងកាន់តែញឹកញាប់។ ដំណើរការស្រដៀងគ្នានេះ ដើម្បីទទួលបានពត៌មានត្រលប់មកវិញអំពីបញ្ហាដែលពាក់ព័ន្ធជាមួយនឹងឧស្សាហកម្មកំពុងធ្វើជាបន្តបន្ទាប់ជាមួយនឹងម្ចាស់រោងចក្រដើម្បីទទួលបានទស្សនៈជារួម ចេញពីការយល់ឃើញផ្សេងៗគ្នាលើបញ្ហាប្រឈមរបស់ឧស្សាហកម្ម។

ព្រឹត្តិប័ត្រនេះ ត្រូវបានបោះពុម្ពផ្សាយដោយគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។
ទស្សនៈទាំងឡាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនជាចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈជាផ្លូវការរបស់អង្គការពលកម្មអន្តរជាតិឡើយ ។

ផ្ទះលេខ ៩ ផ្លូវលេខ ៣២២ សង្កាត់បឹងកេងកងទី ១ ភ្នំពេញ កម្ពុជា – ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ: (៨៥៥_២៣) ២១២ ៨៤៧ លេខបន្ត ១០៦ – ទូរសារ: (៨៥៥_២៣) ២១២ ៩០៣
សម្រាប់ការទទួលយកព្រឹត្តិប័ត្រអេឡិចត្រូនិច សូមចុះឈ្មោះតាមរយៈវិបសាយ www.betterfactories.org/ilo
សម្រាប់ចម្ងល់ផ្សេងៗ សូមទាក់ទងមកកាន់មន្ត្រីទំនាក់ទំនង តាមរយៈអ៊ីម៉េល betterfactories@ilo.org